**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៥១ អនក្រ.បក

ក្រសួងព័ត៌មាន
មកដល់ថ្ងៃទី ១៥.១២.១០
ម៉ោង ... ៥.០០ ...
លេខ ... ១៥៦៣ ... ៣៧

# អនុក្រឹត្យ
## ស្តីពី
## ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/៣៤៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាជាតិអប់រំ

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណានិងនិក្ខេបបទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីលក្ខខណ្ឌ និងយន្តការត្រួតពិនិត្យ សម្រាប់ដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិតប្រកបដោយប្រសិទ្ធភាព។

**មាត្រា ២.-**

អនុក្រឹត្យនេះ មានគោលបំណងដូចតទៅ៖

- បង្កើន និងធានាគុណភាពនិងធ្វើឯកភាពនីយកម្ម ក្នុងការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ជួយគ្រឹះស្ថានឧត្តមសិក្សាផ្សេងៗនិងឯកជន ឲ្យមានភាពងាយស្រួល ក្នុងការរៀបចំការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- ជំរុញនិងលើកទឹកចិត្តចំពោះការស្រាវជ្រាវ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់គ្រឹះស្ថានឧត្តមសិក្សា ដែលធ្វើការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ប្រភេទសញ្ញាបត្របណ្ឌិត

**មាត្រា ៤.-**

សញ្ញាបត្របណ្ឌិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចែកចេញជាពីរប្រភេទ ដូចខាងក្រោម៖

- សញ្ញាបត្របណ្ឌិតស្រាវជ្រាវ ជាប្រភេទសញ្ញាបត្រឧត្តមសិក្សាកម្រិតខ្ពស់បំផុត ដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ ដោយផ្អែកលើការទទួលស្គាល់ស្នាដៃថ្មី ទាំងខាងវិធីសាស្ត្រស្រាវជ្រាវ ទាំងខាងលទ្ធផលនៃការស្រាវជ្រាវ ដែលអាចបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ព្រមទាំងមានការរួមចំណែកក្នុងការសិក្សាស្រាវជ្រាវ សម្រាប់ការបង្កើតចំណេះដឹងនិងការអនុវត្តថ្មី។
- សញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ ជាប្រភេទសញ្ញាបត្រឧត្តមសិក្សាកម្រិតខ្ពស់បំផុត ដែលត្រូវបានប្រគល់ជូនទៅបុគ្គលណាម្នាក់ ដែលបានសិក្សាមុខជំនាញ ដូចជា វេជ្ជសាស្ត្រ ទន្តវេទសាស្ត្រ ឱសថសាស្ត្រ វិស្វកម្ម អប់រំ ធុរកិច្ច និងវិចិត្រសិល្បៈ ជាដើម។ បុគ្គលទទួលសញ្ញាបត្រប្រភេទនេះ បំពេញកិច្ចការជាក់ស្តែងជាចម្បង និងបានចងក្រងចំណេះដឹង ដែលបានពីការសិក្សានិងបទពិសោធការងារទៅតាមវិធីសាស្ត្រ។ បុគ្គលទទួលសញ្ញាបត្របណ្ឌិតប្រភេទនេះ មានបំណងជាចម្បងគឺការបង្កើនសមត្ថភាពវិជ្ជាជីវៈផ្ទាល់ខ្លួន ឲ្យកាន់តែប្រសើរឡើង។ ចំពោះគោរមងារជាព្រឹទ្ធាចារ្យសិល្បៈ មានកម្រិតសមមូលនឹងសញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ។

- សញ្ញាបត្របណ្ឌិតកិត្តិយស ជាសញ្ញាបត្របណ្ឌិតដែលគ្រឹះស្ថានឧត្តមសិក្សា ប្រគល់ជូនបុគ្គលណាម្នាក់ ដោយសារការទទួលស្គាល់ស្នាដៃឆ្នើមកម្រិតខ្ពស់ ដែលមានអត្ថប្រយោជន៍ដល់សង្គម និងមនុស្សជាតិ តាមរយៈសមិទ្ធផលការងារ ការសរសេរសៀវភៅ ឬការផ្សព្វផ្សាយការស្រាវជ្រាវជាដើម។

# ជំពូកទី៣
# លក្ខខណ្ឌសម្រាប់ការបណ្ដុះបណ្ដាលថ្នាក់ បណ្ឌិតស្រាវជ្រាវ និង បណ្ឌិតវិជ្ជាជីវៈ

## ផ្នែកទី១
## លក្ខខណ្ឌសម្រាប់បើកការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត

**មាត្រា ៥..**

គ្រឹះស្ថានឧត្តមសិក្សា ដែលបើកវគ្គបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

៥.១- អង្គភាពទទួលខុសត្រូវ

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង ថ្នាក់បណ្ឌិតមួយច្បាស់លាស់ ស្របនឹងផែនការអភិវឌ្ឍ នៃគ្រឹះស្ថានរបស់ខ្លួន
- អង្គភាពគ្រប់គ្រងថ្នាក់បណ្ឌិត ត្រូវកំណត់អំពីតួនាទី និងភារកិច្ចច្បាស់លាស់ ដើម្បីសម្របសម្រួលតាមកម្មវិធីថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានអង្គភាពគ្រប់គ្រង ដំណើរការស្រាវជ្រាវរបស់និស្សិត។

៥.២- មន្ត្រីទទួលខុសត្រូវ

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានមន្ត្រីដោយឡែក ទទួលបន្ទុកការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់អំពីតួនាទី និងភារកិច្ចរបស់មន្ត្រីម្នាក់ៗ ដែលទទួលបន្ទុកការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត ឲ្យបានច្បាស់លាស់
- ប្រធានអង្គភាពគ្រប់គ្រងថ្នាក់បណ្ឌិត (ឬព្រឹទ្ធបុរសទទួលបន្ទុកថ្នាក់ក្រោយបរិញ្ញាបត្រ) ត្រូវមានសញ្ញាបត្របណ្ឌិត។

៥.៣- ការរៀបចំលិខិតុបករណ៍

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានឯកសារបោះពុម្ពផ្សាយជាផ្លូវការ និងជាសាធារណៈ អំពីនីតិវិធីរដ្ឋបាលសំខាន់ៗ ដែលទាក់ទងនឹងការសិក្សានៅថ្នាក់បណ្ឌិត និងលិខិតបទដ្ឋានដទៃទៀត ចាប់ពីការដាក់ពាក្យចូលសិក្សា រហូតដល់ការបញ្ចប់ការសិក្សា។ ការរៀបរាប់នៅក្នុងលិខិតបទដ្ឋានទាំងនេះ ត្រូវមានភាពច្បាស់លាស់ ងាយយល់ សម្រាប់និស្សិតនិងសាស្ត្រាចារ្យ និងត្រូវមានការផ្សព្វផ្សាយតាមគេហទំព័រ របស់គ្រឹះស្ថានឧត្តមសិក្សា និងមានការបោះពុម្ពផ្សាយយ៉ាងទូលំទូលាយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវធ្វើការកំណត់ឲ្យបានច្បាស់លាស់ អំពីភាពខុសគ្នារវាងនិស្សិតពេញម៉ោង និងនិស្សិតមិនពេញម៉ោង និងត្រូវមានកាលវិភាគច្បាស់លាស់ សម្រាប់ការបញ្ចប់របស់និស្សិតប្រភេទនីមួយៗ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវធ្វើការណែនាំច្បាស់លាស់ អំពីរយៈពេលអប្បបរមា និងអតិបរមានៃការសិក្សាថ្នាក់បណ្ឌិត និងអំពីការទទួលចុះឈ្មោះឡើងវិញរាល់ដើមឆ្នាំសិក្សា ក្នុងកម្មវិធីថ្នាក់បណ្ឌិត

- ការបញ្ចប់ការសិក្សា ដែលហួសពេលកំណត់អតិបរមា ដោយសារមូលហេតុនានា អាចអនុញ្ញាតឲ្យចំពោះតែនិស្សិត ដែលបានដាក់ពាក្យសុំជាផ្លូវការ និងមានការឯកភាពពីសាស្ត្រាចារ្យណែនាំប៉ុណ្ណោះ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានលិខិតបទដ្ឋានច្បាស់លាស់ អំពីនីតិវិធីជាលាយលក្ខណ៍អក្សរ ដែលបង្ហាញអំពីដំណាក់កាលនីមួយៗ នៃកម្មវិធីថ្នាក់បណ្ឌិតសម្រាប់សាស្ត្រាចារ្យនិងនិស្សិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានឯកសារលម្អិតច្បាស់លាស់អំពីក្រមប្រតិបត្តិ និងគោលការណ៍ណែនាំ ដែលធានាតម្លាភាពពាក់ព័ន្ធនឹងភារកិច្ច របស់គ្រប់ភាគីនៅក្នុងកម្មវិធីថ្នាក់បណ្ឌិត រួមមាន និស្សិតថ្នាក់បណ្ឌិតសាស្ត្រាចារ្យណែនាំ មន្ត្រីរដ្ឋបាល និងអ្នកពិនិត្យវាយតម្លៃលើនិក្ខេបបទ។ ចំណុចសំខាន់ៗ ដែលត្រូវបញ្ចូលមានដូចជា៖
    - ក. ជីវិតស្រាវជ្រាវនិងសិក្សា។
    - ខ. ការកំណត់អំពីភាពត្រឹមត្រូវជាម្ចាស់ ក្នុងស្នាដៃនិពន្ធតែម្នាក់ឯង ឬក្នុងស្នាដៃនិពន្ធរួមគ្នា ដែលត្រូវបានបោះពុម្ពផ្សាយ និងការថ្លែងអំណរគុណ ចំពោះអ្នកដែលបានរួមចំណែកទាំងឡាយ។
    - គ. បញ្ហាដែលទាក់ទងនឹងក្រមសីលធម៌និងកម្មសិទ្ធិបញ្ញា។
- គ្រឹះស្ថានឧត្តមសិក្សា អាចចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សានៅក្នុង និងនៅក្រៅប្រទេស ព្រមទាំងជាមួយអង្គការ សហគ្រាសជាតិនិងអន្តរជាតិ ដើម្បីបង្កភាពងាយស្រួល ដល់ការទទួលស្គាល់សញ្ញាបត្របណ្ឌិត និងការអភិវឌ្ឍវិទ្យាសាស្ត្រ
- មុននឹងចាប់ផ្តើមការបណ្តុះបណ្តាល គ្រឹះស្ថានឧត្តមសិក្សា ត្រូវបំពេញបែបបទលើកិច្ចព្រមព្រៀងនិក្ខេបបទ ដែលត្រូវចុះហត្ថលេខា ដោយនិស្សិត សាស្ត្រាចារ្យណែនាំ និងគណៈគ្រប់គ្រងគ្រឹះស្ថានបណ្តុះបណ្តាល។ ក្នុងពេលរៀបចំនិក្ខេបបទ និស្សិតត្រូវបានបញ្ចូលទៅក្នុងអង្គភាពស្រាវជ្រាវ នៃគ្រឹះស្ថានបណ្តុះបណ្តាលរបស់ខ្លួន
- មុននឹងចាប់ផ្តើមការបណ្តុះបណ្តាលថ្នាក់បណ្ឌិត គ្រឹះស្ថានឧត្តមសិក្សា ត្រូវធានាថា លក្ខខណ្ឌវិទ្យាសាស្ត្រ សម្ភារៈ និងហិរញ្ញវត្ថុ ត្រូវបានត្រៀមជាស្រេច ដើម្បីធានាដំណើរការល្អនៃការបណ្តុះបណ្តាល។

**មាត្រា ៦.-**

លក្ខខណ្ឌសម្រាប់សាស្ត្រាចារ្យ មានដូចខាងក្រោម៖

៦.១- ប្រភេទសាស្ត្រាចារ្យណែនាំ

- សាស្ត្រាចារ្យណែនាំនិស្សិតមានពីរប្រភេទគឺ សាស្ត្រាចារ្យណែនាំគោល និងសាស្ត្រាចារ្យណែនាំរង ឬសហសាស្ត្រាចារ្យណែនាំ
- សាស្ត្រាចារ្យណែនាំគោល គឺជាសាស្ត្រាចារ្យណែនាំទីមួយ និងជាបុគ្គលិកសិក្សា ដែលមានសញ្ញាបត្របណ្ឌិតលើមុខវិជ្ជាសមស្រប ជាមួយនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត និងមានបទពិសោធស្រាវជ្រាវ ឬការបង្រៀនច្បាស់លាស់។ សាស្ត្រាចារ្យណែនាំគោល ត្រូវជាសាស្ត្រាចារ្យពេញម៉ោងរបស់គ្រឹះស្ថានឧត្តមសិក្សាផ្ទាល់ និងជាបញ្ញវន្តដែលសកម្ម និងមានជោគជ័យក្នុងជំនាញរបស់ខ្លួន
- សាស្ត្រាចារ្យណែនាំរង ឬសហសាស្ត្រាចារ្យណែនាំ គឺជាសាស្ត្រាចារ្យ ឬអ្នកជំនាញ ដែលសហការណែនាំ ជាមួយនឹងសាស្ត្រាចារ្យណែនាំគោល និងដែលមានសញ្ញាបត្របណ្ឌិតលើមុខវិជ្ជាសមស្រប ជាមួយនឹងប្រធានបទស្រាវជ្រាវរបស់និស្សិត និងមានបទពិសោធស្រាវជ្រាវឬបង្រៀនសមស្រប។

### ៦.២- ការបណ្តុះបណ្តាលនិងការជួយគាំទ្រនិស្សិត

- និស្សិតថ្នាក់បណ្ឌិតម្នាក់ៗ មានសាស្ត្រាចារ្យណែនាំគោលម្នាក់
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់លក្ខខណ្ឌច្បាស់លាស់ អំពីនិរន្តរភាពរបស់សាស្ត្រាចារ្យណែនាំគោលក្នុងការណែនាំនិស្សិតម្នាក់ៗ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមាននីតិវិធីច្បាស់លាស់ ដើម្បីកំណត់សមត្ថភាពនិងលទ្ធភាពរបស់សាស្ត្រាចារ្យម្នាក់ៗ ក្នុងការទទួលយកនិស្សិតមកណែនាំ។ នីតិវិធីទាំងនេះ ត្រូវរាប់បញ្ចូលនូវបទពិសោធ កេរ្តិ៍ឈ្មោះ និងជោគជ័យរបស់សាស្ត្រាចារ្យ និងក្រុមរបស់សាស្ត្រាចារ្យនោះ ក្នុងការណែនាំនិស្សិតថ្នាក់បណ្ឌិត និងក្នុងការស្រាវជ្រាវនានា
- ចំនួននិស្សិតដែលសាស្ត្រាចារ្យណែនាំគោលម្នាក់ៗ អាចណែនាំបាន មានការប្រែប្រួលតាមជំនាញ។ ក្នុងគ្រប់ករណី សាស្ត្រាចារ្យម្នាក់មិនអាចមាននិស្សិតក្នុងបន្ទុកណែនាំ នៅថ្នាក់បណ្ឌិតលើសពី ៥ (ប្រាំបួន) រូបឡើយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានគោលការណ៍អំពីការលាឈប់ ឬការចូលនិវត្តន៍របស់សាស្ត្រាចារ្យណែនាំ។ ត្រូវមានសាស្ត្រាចារ្យណែនាំស្តីទីទទួលខុសត្រូវបន្តជាបន្ទាន់ នៅពេលដែលសាស្ត្រាចារ្យណែនាំគោលលាឈប់ ឬចូលនិវត្តន៍។

### ៦.៣- ភារកិច្ចនិងការទទួលខុសត្រូវរបស់សាស្ត្រាចារ្យ

- សាស្ត្រាចារ្យណែនាំមានភារកិច្ច ជួយនិស្សិតឲ្យបញ្ចប់ការស្រាវជ្រាវ របស់ខ្លួនតាមកាលកំណត់។ ភារកិច្ចសំខាន់ៗរួមមាន ៖
  - ក- ណែនាំដល់និស្សិតអំពីការរៀបចំគម្រោងពេលវេលានៃការស្រាវជ្រាវ។
  - ខ- ផ្តល់ដល់និស្សិតនូវការណែនាំផ្នែកវិទ្យាសាស្ត្រ។
  - គ- ធ្វើការវាយតម្លៃលើការរីកចម្រើននៃការស្រាវជ្រាវ។
  - ឃ- ជួយសម្របសម្រួលផ្នែករដ្ឋបាល។
  - ង- ណែនាំអំពីវិធីសាស្ត្រឧបករណ៍ និងសម្ភារៈនានាទាក់ទងនឹងការស្រាវជ្រាវរបស់និស្សិត។
  - ច- ផ្តល់ការណែនាំដល់និស្សិត ដើម្បីមានទំនាក់ទំនងទូលំទូលាយ ជាមួយនឹងអ្នកជំនាញនានា។
  - ឆ- លើកទឹកចិត្តនិស្សិតឲ្យចូលរួមក្នុងសកម្មភាពសិក្សានិងស្រាវជ្រាវ។
- គ្រប់សាស្ត្រាចារ្យណែនាំគោលនិងសាស្ត្រាចារ្យណែនាំរង ឬសហសាស្ត្រាចារ្យណែនាំ ត្រូវយល់អំពី៖
  - ក- ភារកិច្ចនិងសិទ្ធិរបស់ខ្លួនជាសាស្ត្រាចារ្យចំពោះនិស្សិតថ្នាក់បណ្ឌិតដែលខ្លួនណែនាំ។
  - ខ- ភារកិច្ចនិងសិទ្ធិរបស់និស្សិតថ្នាក់បណ្ឌិត ក្រោមការណែនាំរបស់ខ្លួន។
  - គ- បញ្ញត្តិទាំងឡាយស្តីពីកម្មវិធីវគ្គបណ្ឌិតនិងការពិនិត្យវាយតម្លៃលើថ្នាក់បណ្ឌិត។
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់អំពីលក្ខខណ្ឌ ដែលតម្រូវឲ្យមានសហសាស្ត្រាចារ្យណែនាំ
- ក្នុងករណីដែលសាស្ត្រាចារ្យណែនាំ ឬនិស្សិត អវត្តមានក្នុងរយៈពេលវែង ដោយមូលហេតុណាមួយ គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់ច្បាស់លាស់ អំពីការរក្សាផលប្រយោជន៍របស់សាស្ត្រាចារ្យណែនាំនិងនិស្សិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់ច្បាស់លាស់អំពីនីតិវិធី នៃការផ្លាស់ប្តូរសាស្ត្រាចារ្យណែនាំគោល ឬសហសាស្ត្រាចារ្យណែនាំ

- តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សាបរទេសជាដៃគូ អាចផ្តល់សាស្ត្រាចារ្យណែនាំរបស់ខ្លួន ឲ្យបំពេញភារកិច្ចជាសហសាស្ត្រាចារ្យណែនាំ
- តាមរយៈកិច្ចព្រមព្រៀង អង្គការ ឬសហគ្រាសជាដៃគូ អាចផ្តល់អ្នកជំនាញដែលមានគ្រប់លក្ខណៈវិនិច្ឆ័យ សម្រាប់ការណែនាំឲ្យចូលរួមបំពេញភារកិច្ច ជាសហសាស្ត្រាចារ្យណែនាំ
- ក្រុមប្រឹក្សាវិទ្យាសាស្ត្រនៃគ្រឹះស្ថានបណ្តុះបណ្តាល ត្រូវចូលរួមក្នុងការកំណត់អំពីលក្ខខណ្ឌ និងការរៀបចំនីតិវិធីខាងលើ។

**មាត្រា ៧.-**

លក្ខខណ្ឌសម្រាប់និស្សិត មានដូចខាងក្រោម៖

**៧.១- ការជ្រើសរើសនិស្សិត**

- ចំនួននិស្សិតដែលត្រូវជ្រើសរើស ត្រូវសមស្របជាមួយនឹងធនធាន របស់គ្រឹះស្ថានឧត្តមសិក្សា
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីលក្ខខណ្ឌ នៃការជ្រើសរើសនិស្សិតចូលសិក្សាថ្នាក់បណ្ឌិត។ លក្ខខណ្ឌជាមូលដ្ឋាននៃការជ្រើសរើសនិស្សិតមានដូចជា៖

  ក- ការឆ្លងកាត់ការសិក្សាគ្រប់ភូមិសិក្សា ដែលមានលក្ខណៈជាប្រព័ន្ធ និងប្រក្រតី។

  ខ- ពិន្ទុខ្ពស់ក្នុងកម្រិតសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

  គ- សមត្ថភាពក្នុងការស្រាវជ្រាវ។

  ឃ- ចំណេះដឹងភាសាបរទេស។

  ង- ពិន្ទុនៃការប្រឡងចូល និងសេចក្តីស្នើគម្រោងស្រាវជ្រាវរបស់និស្សិត។

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវពិនិត្យលទ្ធភាពក្នុងការផ្តល់ការសិក្សាថ្នាក់បណ្ឌិត ឲ្យនិស្សិតបរទេសអាចមានឱកាសបានចូលសិក្សាផងដែរ។ សាស្ត្រាចារ្យណែនាំនិស្សិតបរទេស ត្រូវបានលើកទឹកចិត្ត និងទទួលការគាំទ្រ។

**៧.២- ភារកិច្ចនិងការទទួលខុសត្រូវ**

ការបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតដោយជោគជ័យ តម្រូវឲ្យមានការអភិវឌ្ឍសមត្ថភាពជំនាញនិងទំនុកចិត្តលើខ្លួនឯង។ និស្សិតទាំងអស់ត្រូវមានភារកិច្ចនិងការទទួលខុសត្រូវលើការស្រាវជ្រាវ ដោយឯករាជ្យ ក្រោមការដឹកនាំរបស់សាស្ត្រាចារ្យណែនាំ សំដៅអភិវឌ្ឍបញ្ញាញាណផ្ទាល់ខ្លួន។ ភារកិច្ចនិងការទទួលខុសត្រូវទាំងនោះមានដូចជា៖

ក- ការលើកផែនការនិងធ្វើការស្រាវជ្រាវយ៉ាងសកម្ម។

ខ- ការកំណត់និងដោះស្រាយបញ្ហាក្នុងការស្រាវជ្រាវ។

គ- ការឆ្លើយតបតាមតម្រូវការរដ្ឋបាលរបស់គ្រឹះស្ថានឧត្តមសិក្សា។

ឃ- ការគោរពក្រមសីលធម៌ជាអ្នកស្រាវជ្រាវ។

ង- ការបោះពុម្ពផ្សាយស្រាវជ្រាវក្នុងទស្សនាវដ្តី ឬវេទិកា ដែលមានលក្ខណៈវិទ្យាសាស្ត្រ ឬវិជ្ជាជីវៈ។

ច- ការទទួលខុសត្រូវលើនិក្ខេបបទចុងក្រោយរបស់ខ្លួន។

ឆ- ការចូលរួមយ៉ាងសកម្មក្នុងជីវភាពសិក្សានៃគ្រឹះស្ថានឧត្តមសិក្សា។

# ជំពូកទី២
## លក្ខខណ្ឌសម្រាប់ដំណើរការការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

**មាត្រា ៨.-**

លក្ខខណ្ឌនៃការបណ្តុះបណ្តាល មានដូចខាងក្រោម៖

៨.១- ចរិតនៃការបណ្តុះបណ្តាល

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់គោលការណ៍ ក្នុងការបណ្តុះបណ្តាលឲ្យបានច្បាស់លាស់ គ្រឹះស្ថានឧត្តមសិក្សា ត្រូវរៀបចំកម្មវិធីសិក្សាថ្នាក់បណ្ឌិត ឲ្យមានសមាសភាគនៃចំណេះដឹងកម្រិតខ្ពស់។ សមាសភាគនេះមានដូចជា៖
  - ក- ការសិក្សាវិធីសាស្ត្រស្រាវជ្រាវ និងវិធីសាស្ត្រនានា នៃការវិភាគទិន្នន័យ។
  - ខ- ការសិក្សាដែលផ្តល់ចំណេះដឹងខ្ពស់ពាក់ព័ន្ធនឹងទ្រឹស្តី និងការអនុវត្តវិជ្ជាជីវៈ សក្តិសមនឹងជំនាញ និងកម្រិតសញ្ញាបត្រ។
  - គ- សកម្មភាពរៀបចំឡើង ដើម្បីពង្រីកចំណេះដឹងរបស់និស្សិត ក្នុងការស្រាវជ្រាវស្របតាមជំនាញ។

គ្រឹះស្ថានឧត្តមសិក្សា ត្រូវបង្កើតលក្ខណៈវិនិច្ឆ័យលើលទ្ធផល នៃការស្រាវជ្រាវនិងអត្ថបទបោះពុម្ព និងបង្កើតគោលការណ៍ នៃការផ្សព្វផ្សាយលទ្ធផល នៃការស្រាវជ្រាវនិងអត្ថបទបោះពុម្ព។ លក្ខណៈវិនិច្ឆ័យនិងគោលការណ៍នេះ ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដល់និស្សិតនិងសាស្ត្រាចារ្យ

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតស្រាវជ្រាវ ត្រូវសង្កត់ធ្ងន់ទាំងលើលទ្ធផលនៃការស្រាវជ្រាវ ដែលខុសប្លែកពីការបណ្តុះបណ្តាលថ្នាក់បណ្ឌិតវិជ្ជាជីវៈ ដែលសង្កត់ធ្ងន់លើលទ្ធផល នៃការសិក្សាទាំងលើការស្រាវជ្រាវ។

៨.២- រចនាសម្ព័ន្ធនិងរយៈពេលនៃការបណ្តុះបណ្តាល

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានសេចក្តីប្រកាសច្បាស់លាស់ អំពីរយៈពេលសិក្សាស្រាវជ្រាវ នៃថ្នាក់បណ្ឌិត។ ថ្នាក់បណ្ឌិតមានរយៈពេលពី៣(បី)ទៅ៦(ប្រាំមួយ)ឆ្នាំ សម្រាប់ថ្នាក់ បណ្ឌិតពេញម៉ោង និងរហូតដល់៨(ប្រាំបី)ឆ្នាំ សម្រាប់ថ្នាក់បណ្ឌិតមិនពេញម៉ោង

ក្នុងករណីពិសេស សម្រាប់ថ្នាក់បណ្ឌិតវិជ្ជាជីវៈ តាមសំណើរបស់ស្ថាប័នជំនាញដែលជាស្ថាប័នសាមីដោយមានការឯកភាព ពីក្រសួងទទួលបន្ទុកវិស័យអប់រំ គ្រឹះស្ថានឧត្តមសិក្សា អាចធ្វើការវាយតម្លៃលើលទ្ធផលស្នាដៃថ្មីរបស់បេក្ខជន។ មុននឹងទទួលសញ្ញាបត្របណ្ឌិតវិជ្ជាជីវៈ បេក្ខជនប្រភេទនោះ ត្រូវចងក្រងលទ្ធផលស្រាវជ្រាវរបស់ខ្លួនជានិក្ខេបបទ និងដាក់ជូនគ្រឹះស្ថានឧត្តមសិក្សា ដើម្បីប្រគល់ជូនអ្នកពិនិត្យវាយតម្លៃ និងធ្វើការការពារនៅចំពោះមុខគណៈកម្មការការពារនិក្ខេបបទ

ការសិក្សាថ្នាក់បណ្ឌិតចែកចេញជាបីដំណាក់កាល៖

ក-ដំណាក់កាលទី១ គឺការសិក្សានិងការកែលម្អបញ្ចប់ និងការការពារគម្រោងស្នើស្រាវជ្រាវ។ និស្សិតត្រូវប្រឡងបញ្ចប់ការសិក្សាកម្រិតអប្បបរមា (ទាំងមុខជំនាញទាំងភាសាបរទេស) ដោយជោគជ័យ ទើបអាចបន្តទៅដំណាក់កាលទី២បាន។

ខ-ដំណាក់កាលទី២ គឺការស្រាវជ្រាវ (និងការសិក្សាបន្ត សម្រាប់ថ្នាក់បណ្ឌិតវិជ្ជាជីវៈ) ការបោះពុម្ពផ្សាយលទ្ធផលនៃការស្រាវជ្រាវ និងការរៀបចំនិក្ខេបបទ។

គ-ដំណាក់កាលទី៣ គឺការសរសេរបញ្ចប់និក្ខេបបទ និងការការពារនិក្ខេបបទ។

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវរៀបចំឲ្យនិស្សិតធ្វើបទបង្ហាញ និងការការពារយ៉ាងតិចពីរដំណាក់កាលមុននឹងមានការការពារបញ្ចប់។ បទបង្ហាញនិងការការពារទាំងពីរដំណាក់កាលនោះគឺ
  - ក-បទបង្ហាញនិងការការពារគម្រោងស្រាវជ្រាវ (ការការពារគម្រោង)។
  - ខ-បទបង្ហាញនិងការការពារលទ្ធផលស្រាវជ្រាវបឋម (ការបង្ហាញអំពីការរីកចម្រើននៃការស្រាវជ្រាវ)។

៨.៣- គណៈកម្មការនិងក្រុមទទួលបន្ទុកការបណ្តុះបណ្តាល

គណៈកម្មការនិងក្រុមសាស្ត្រាចារ្យ ឬអ្នកជំនាញមានបួនប្រភេទ ក្នុងដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ គណៈកម្មការនិងក្រុមទាំងបួននោះគឺ៖

- គណៈកម្មការទទួលខុសត្រូវថ្នាក់បណ្ឌិត ដែលជាក្រុមសាស្ត្រាចារ្យ និងថ្នាក់ដឹកនាំ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ដែលត្រូវបានបង្កើតឡើងដោយគ្រឹះស្ថានឧត្តមសិក្សា ដើម្បីលើកគោលការណ៍ និងត្រួតពិនិត្យទូទៅលើថ្នាក់បណ្ឌិត
- ក្រុមសាស្ត្រាចារ្យណែនាំនិស្សិតថ្នាក់បណ្ឌិត ដែលត្រូវបានបង្កើតឡើងដោយគ្រឹះស្ថានឧត្តមសិក្សា និងមានសមាជិកជាសាស្ត្រាចារ្យ និង/ឬជាបុគ្គលដែលមានសមត្ថភាព ដូចមានចែងក្នុងអនុក្រឹត្យនេះដើម្បីណែនាំកិច្ចការសិក្សានិងស្រាវជ្រាវរបស់និស្សិតម្នាក់ៗ
- ក្រុមអ្នកពិនិត្យវាយតម្លៃលើនិក្ខេបបទ។ ក្រុមនេះ គឺជាក្រុមអ្នកជំនាញ ដែលមានភារកិច្ចពិនិត្យវាយតម្លៃលើនិក្ខេបបទ មុនពេលនិក្ខេបបទត្រូវបានការពារបញ្ចប់។ សមាជិកនៃក្រុមនេះមាននៅក្នុងនិងនៅក្រៅគ្រឹះស្ថានឧត្តមសិក្សា។ ក្រសួងទទួលបន្ទុកវិស័យអប់រំមានភារកិច្ចរៀបចំបញ្ជីឈ្មោះក្រុមសាស្ត្រាចារ្យនិងអ្នកជំនាញ ដើម្បីសម្រួលដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការជ្រើសរើសអ្នកពិនិត្យនិងវាយតម្លៃមកពីខាងក្រៅគ្រឹះស្ថានឧត្តមសិក្សា
- គណៈកម្មការការពារនិក្ខេបបទបញ្ចប់ ត្រូវបានរៀបចំឡើងដោយគ្រឹះស្ថានឧត្តមសិក្សា និងមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យអប់រំ។ ចំនួនសមាជិកនៃគណៈកម្មការនេះមានចែងក្នុងផ្នែកទីបីនៃអនុក្រឹត្យនេះ។ សមាជិកនៃគណៈកម្មការនេះមានមកពីថ្នាក់ដឹកនាំគ្រឹះស្ថានឧត្តមសិក្សាសាស្ត្រាចារ្យណែនាំ អ្នកពិនិត្យវាយតម្លៃលើនិក្ខេបបទ តំណាងក្រសួងទទួលបន្ទុកវិស័យអប់រំ និងអង្គភាពដទៃទៀតក្នុងករណីចាំបាច់។

៨.៤- បរិយាកាសនៃការបណ្តុះបណ្តាល

- គ្រឹះស្ថានឧត្តមសិក្សា អាចមានកិច្ចសហប្រតិបត្តិការ ជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សា ក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីពង្រីកឱកាសសម្រាប់និស្សិតថ្នាក់បណ្ឌិត ក្នុងការទទួលយកជំនាញពីគ្រឹះស្ថានឧត្តមសិក្សាដទៃ ក៏ដូចជាពីសាស្ត្រាចារ្យបរទេស
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការណែនាំអំពីគម្រិតអប្បបរមា នៃការពិភាក្សាពីគ្រោះយោបល់រវាងនិស្សិត និងសាស្ត្រាចារ្យណែនាំ និងត្រូវមានជម្រើសសមរម្យនៅពេលដែលកម្រិតនៃការជួបពិភាក្សានេះ មិនអាចធ្វើទៅកើតដោយសារមូលហេតុណាមួយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានយន្តការដោយឡែក សម្រាប់និស្សិតដែលគម្រោងស្រាវជ្រាវមានលក្ខណៈពិសេសដោយឡែក និងត្រូវមានការផ្តល់ជូន នូវការគាំទ្រមួយសមស្រប ដល់គម្រោងស្រាវជ្រាវបែបនេះ

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបោះពុម្ពផ្សាយប្រចាំឆ្នាំ នូវបញ្ជីឈ្មោះនិស្សិតថ្នាក់បណ្ឌិត ប្រធានបទនិក្ខេបបទ និងឈ្មោះសាស្ត្រាចារ្យណែនាំ ដើម្បីជំរុញឲ្យមានទំនាក់ទំនងគ្នាកាន់តែប្រសើរ រវាងនិស្សិតថ្នាក់បណ្ឌិត និងអ្នកស្រាវជ្រាវផងទៀត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានគោលការណ៍ណែនាំអំពីសម្ភារៈនានា ដែលប្រើប្រាស់ដោយនិស្សិតថ្នាក់បណ្ឌិត រួមទាំងលក្ខណៈពិសេសនៃការប្រើប្រាស់បណ្ណាល័យ ការខ្ចីសៀវភៅឆ្លងបណ្ណាល័យ និងសិទ្ធិប្រើប្រាស់សម្ភារៈមួយចំនួន របស់បុគ្គលិកនៃគ្រឹះស្ថានឧត្តមសិក្សា។

**មាត្រា ៩.-**

លក្ខខណ្ឌដែលពាក់ព័ន្ធនឹងប្រធានបទនិក្ខេបបទ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងនិស្សិត និងប្រធានបទស្រាវជ្រាវរបស់និស្សិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានក្រុមសីលធម៌សម្រាប់ការស្រាវជ្រាវក្នុងវិស័យនីមួយៗ និងមានយន្តការសម្រាប់ធានាថាប្រធានបទនៃការស្រាវជ្រាវមានផលប្រយោជន៍ដល់សង្គម និងស្របតាមតម្រូវការរបស់ប្រទេស និងមនុស្សជាតិ។
- និស្សិតនិងសាស្ត្រាចារ្យណែនាំ ត្រូវមានការយល់ដឹងអំពីគោលនយោបាយរបស់គ្រឹះស្ថានឧត្តមសិក្សាលើកម្មសិទ្ធិបញ្ញា។ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានផ្តល់ព័ត៌មានអំពីបញ្ហាទាក់ទងនឹងកម្មសិទ្ធិបញ្ញានៅពេលដែលបញ្ហានេះបានលេចឡើងដោយមូលហេតុណាមួយ។

**មាត្រា ១០.-**

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានក្រមប្រតិបត្តិស្តីពីសិទ្ធិ និងការទទួលខុសត្រូវរបស់និស្សិតថ្នាក់បណ្ឌិត សាស្ត្រាចារ្យណែនាំ និងគ្រឹះស្ថានឧត្តមសិក្សាផ្ទាល់។ ក្រមប្រតិបត្តិនេះ ត្រូវបានចែកជូនដល់គ្រប់ភាគីពាក់ព័ន្ធ។

**មាត្រា ១១.-**

ការបោះពុម្ពនិងការចូលរួមសិក្ខាសាលា មានដូចខាងក្រោម៖

- និស្សិតថ្នាក់បណ្ឌិត ត្រូវមានបទបង្ហាញអំពីលទ្ធផលស្រាវជ្រាវរបស់ខ្លួននៅក្នុងសិក្ខាសាលាឬសន្និសីទជាតិ ឬអន្តរជាតិ
- មុនពេលប្រគល់និក្ខេបបទដើម្បីការពារជាចុងក្រោយ និស្សិត ត្រូវមានអត្ថបទបោះពុម្ពផ្សាយជាសាធារណៈដែលទាក់ទងនឹងប្រធានបទនិក្ខេបបទយ៉ាងតិចមួយអត្ថបទ នៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ ឬទស្សនាវដ្តីបោះពុម្ពដោយសមាគមវិជ្ជាជីវៈ។

**មាត្រា ១២.-**

ការត្រួតពិនិត្យកម្មវិធីថ្នាក់បណ្ឌិត មានដូចខាងក្រោម៖

១២.១- ការត្រួតពិនិត្យ

- គ្រឹះស្ថានឧត្តមសិក្សា ដែលមានវគ្គបណ្ឌិត ត្រូវមាននីតិវិធីដើម្បីធានាស្តង់ដាគុណភាព នៃកម្មវិធីថ្នាក់បណ្ឌិត ដែលមានជាអាទិ៍៖

ក- ការពិនិត្យឡើងវិញតាមកាលកំណត់លើផ្នែកនីមួយៗនៃថ្នាក់បណ្ឌិត។

ខ- ការអង្កេតតាមកាលកំណត់ ដើម្បីស្វែងយល់អំពីការពេញចិត្ត របស់និស្សិតថ្នាក់បណ្ឌិតលើកម្មវិធីថ្នាក់បណ្ឌិត។

គ- ការអង្កេតលើការបញ្ចប់របស់និស្សិតថ្នាក់បណ្ឌិត។

ឃ- ការចងក្រងនិងការបោះពុម្ព នូវពេលវេលានិងអត្រានៃការបញ្ចប់ និងទិន្នន័យដទៃទៀតដែលអាចឆ្លុះឲ្យឃើញអំពីការបំពេញការកិច្ចរបស់ផ្នែកនីមួយៗនៃគ្រឹះស្ថានឧត្តមសិក្សា។

- ការត្រួតពិនិត្យរបស់គ្រឹះស្ថានឧត្តមសិក្សា មានដូចជា៖

ក- ការជួបប្រជុំគ្នាដំបូងរវាងនិស្សិតថ្នាក់បណ្ឌិតនិងក្រុមសាស្ត្រាចារ្យណែនាំ ដើម្បីកំណត់នីតិវិធីក្នុងការស្រាវជ្រាវឲ្យមានការឯកភាពគ្នា។ ក្នុងកិច្ចប្រជុំដំបូងនេះ គម្រោងស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិត ត្រូវបានលើកយកមកពិភាក្សាលម្អិត។

ខ- ការកំណត់ឲ្យនិស្សិតរៀបចំផែនការ សម្រាប់ការស្រាវជ្រាវ និងការកំណត់ចន្លោះពេលពីដំណាក់កាលមួយ ទៅដំណាក់កាលមួយទៀត នៃការស្រាវជ្រាវ។

គ- ការវាយតម្លៃលើការវិវត្តទៅរបស់និស្សិត ពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត។

ឃ-ការវាយតម្លៃជាទៀងទាត់ ដោយមានការកត់ត្រាជាលាយលក្ខណ៍អក្សរប្រកប ដោយតម្លាភាពក្នុងការវាយតម្លៃ ដើម្បីកំណត់ការរីកចម្រើននៃការស្រាវជ្រាវ។

ង- ការឯកភាពគ្នារបស់ក្រុមសាស្ត្រាចារ្យណែនាំ អំពីលទ្ធផលនៃការវាយតម្លៃលើការវិវត្ត នៃការស្រាវជ្រាវរបស់និស្សិតមុនពេលអនុញ្ញាត ឲ្យមានការបន្តការស្រាវជ្រាវតទៅទៀត។

១២.២- ការប្តឹងតវ៉ា

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមាននីតិវិធីច្បាស់លាស់ ងាយយល់ ក្នុងការប្តឹងតវ៉ា។ និស្សិតម្នាក់ៗ អាចប្តឹងតវ៉ាពេលណាក៏បានអំពីបញ្ហា ដែលទាក់ទងនឹងគម្រោងស្រាវជ្រាវ និងសាស្ត្រាចារ្យណែនាំរបស់ខ្លួន។ យន្តការបណ្តឹងនេះផ្តើមចេញពីការតវ៉ា មិនផ្លូវការនៅគ្រាដំបូងៗ និងឈានទៅការប្តឹងតវ៉ាជាផ្លូវការនៅកាលៈទេសៈមួយដែលសមស្រប។ នីតិវិធីនៃការប្តឹងតវ៉ា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យអប់រំ។

**មាត្រា ១៣..**

ចំណុចពាក់ព័ន្ធនឹងនិក្ខេបបទ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ជាក់ច្បាស់លាស់នៅក្នុងការណែនាំរបស់ខ្លួនអំពីទម្រង់និងកត្តាធានាគុណភាពដទៃទៀតនៃនិក្ខេបបទ។ ទម្រង់និងកត្តាធានាគុណភាពនេះ អាចមានភាពខុសប្លែកខ្លះៗ ទៅតាមជំនាញនីមួយៗ។ ជារួម និក្ខេបបទថ្នាក់បណ្ឌិតមួយសមមូលនឹងអត្ថបទ ដែលអាចបោះពុម្ពបាននៅក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រ យ៉ាងតិចចំនួន២(ពីរ)អត្ថបទ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានសេវាហើស និងប្រកបដោយប្រសិទ្ធភាព ដើម្បីជួយនិស្សិតក្នុងការសរសេរនិក្ខេបបទ។ សេវាទាំងនេះមានដូចជា៖

ក- ផែនការការងារជាប្រព័ន្ធ រួមទាំងការពិគ្រោះយោបល់តាមកាលកំណត់ ជាមួយនឹងសាស្ត្រាចារ្យណែនាំគោល។

ខ- ការបណ្តុះបណ្តាលបន្ថែម អំពីការរៀបចំផែនការការងារ បែបបទនៃការសរសេរវិធីសាស្ត្រ និងការប្រើកុំព្យូទ័រ។

គ- ផ្តល់សម្ភារៈចាំបាច់ដើម្បីសរសេរនិក្ខេបបទ ដូចជាការប្រើប្រាស់កុំព្យូទ័ររបស់គ្រឹះស្ថានឧត្តមសិក្សា។

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ថ្ងៃចុងក្រោយ ក្នុងឆ្នាំសិក្សានីមួយៗ ក្នុងការទទួលនិក្ខេបបទ និងទុករយៈពេលសមស្របមួយ ដើម្បីឱ្យមានការពិនិត្យវាយតម្លៃ ការកែលម្អ និងការសរសេរតាមការណែរបស់អ្នកពិនិត្យ និងវាយតម្លៃ

- និស្សិត អាចធ្វើការសម្រេចចិត្ត ក្នុងការសរសេរនិក្ខេបបទបញ្ចប់ និងការប្រគល់និក្ខេបបទ ទៅគ្រឹះស្ថានឧត្តមសិក្សា ដើម្បីស្នើសុំការធ្វើការការពារ ក្រោយពេលទទួលការណែនាំ ពីក្រុមសាស្ត្រាចារ្យណែនាំ
- និក្ខេបបទ ត្រូវយកទៅតម្កល់ទុកនៅបណ្ណាល័យ/បណ្ណសារដ្ឋានជាតិកម្ពុជា ក្រោយពេលការការពារបញ្ចប់ដោយជោគជ័យ។

## ផ្នែកទី៣
## លក្ខខណ្ឌសម្រាប់ការបញ្ចប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

**មាត្រា ១៤.**

ការប្រឡងបញ្ចប់ការសិក្សា មានដូចខាងក្រោម៖

១៤.១- លក្ខខណ្ឌទូទៅ

- និស្សិត ត្រូវបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាសិក្សា គ្រប់ជំហាននៃដំណើរការបណ្តុះបណ្តាលមុនពេលប្រគល់និក្ខេបបទ សម្រាប់ការពិនិត្យ និងការវាយតម្លៃ
- ការចេញសញ្ញាបត្របណ្ឌិត ត្រូវផ្អែកលើគោលការណ៍នៃការវាយតម្លៃឯករាជ្យពីខាងក្រៅ ដោយគ្មានភាពលម្អៀង ទៅលើគុណភាពនៃស្នាដៃស្រាវជ្រាវ និងត្រូវធ្វើឡើងអាស្រ័យលើលទ្ធផល នៃការការពារជាចុងក្រោយ ដោយមិនគិតអំពីការសិក្សាមុនៗ។
- បេក្ខជន ត្រូវទទួលបាននូវការពន្យល់អំពីបែបបទ នៃការប្រឡងបញ្ចប់ និងកាលបរិច្ឆេទនៃការប្រឡងបញ្ចប់មិនតិច ជាង៤(បួន)ខែមុន។

១៤.២- យន្តការត្រួតពិនិត្យវាយតម្លៃនិក្ខេបបទ និងរបាយការណ៍

- ការប្រឡងបញ្ចប់រួមមានការពិនិត្យវាយតម្លៃ របស់អ្នកជំនាញលើនិក្ខេបបទ ដោយអ្នកពិនិត្យវាយតម្លៃនិក្ខេបបទ៣(បី)រូប រួមនឹងការការពារដោយផ្ទាល់មាត់ពីបេក្ខជនបណ្ឌិត និងជាសាធារណៈនៅពេលការពារនិក្ខេបបទ
- គណៈមេប្រយោគជាអ្នកទទួលខុសត្រូវ លើការពិនិត្យរបាយការណ៍ទាំងអស់ និងវាយតម្លៃលើលទ្ធផលនៃដំណើរការប្រឡងជាទូទៅ។ គណៈមេប្រយោគមានសមាសភាពពី៥(ប្រាំ) ទៅ៧(ប្រាំពីរ) រូប ដែល ក្នុងនោះមានទាំងអ្នកពិនិត្យវាយតម្លៃ៣(បី)រូបផងដែរ
- និក្ខេបបទត្រូវមានការពិនិត្យវាយតម្លៃពីសំណាក់អ្នកពិនិត្យវាយតម្លៃ៣(បី)រូប ដែលជាអ្នកមានសញ្ញាបត្របណ្ឌិត និងស្នាដៃថ្មីក្នុងវិស័យរបស់និក្ខេបបទ និងជាទូទៅមានបទពិសោធក្នុងការដឹកនាំការសរសេរនិក្ខេបបទ និងពិនិត្យវាយតម្លៃនិក្ខេបបទ។ ក្នុងចំណោមអ្នកពិនិត្យនិងវាយតម្លៃនិក្ខេបបទទាំងបីនាក់មាន២(ពីរ)រូបជាអ្នកខាងក្រៅ គ្រឹះស្ថានឧត្តមសិក្សា និង១(មួយ)រូបជាបុគ្គលិករបស់គ្រឹះស្ថានឧត្តមសិក្សា ដែលប្រគល់សញ្ញាបត្រ។ អ្នកពិនិត្យនិងវាយតម្លៃមកពីខាងក្រៅ អាចជាសាស្ត្រាចារ្យមកពីគ្រឹះស្ថានឧត្តមសិក្សា នៅកម្ពុជាឬបរទេស។ ក្នុងករណីដែលបេក្ខជនបណ្ឌិតជាបុគ្គលិកនៃគ្រឹះស្ថានឧត្តមសិក្សា ដែលប្រគល់សញ្ញាបត្រ អ្នកពិនិត្យនិងវាយតម្លៃខាងក្នុងគ្រឹះស្ថានឧត្តមសិក្សាមិនអាចជាសាច់ញាតិ មិត្តភក្តិ ឬអ្នករួមការងារជិតដិតនឹងបេក្ខជនបានឡើយ
- អ្នកពិនិត្យវាយតម្លៃ មិនអាចជាសាស្ត្រាចារ្យណែនាំនិស្សិតនោះបានឡើយ

- អ្នកពិនិត្យវាយតម្លៃនិក្ខេបបទ គឺជាអ្នកដែលពុំមានទំនាក់ទំនងបុគ្គល ទំនាក់ទំនងវិជ្ជាជីវៈ ឬជាប់កិច្ចសន្យាណាមួយ ជាមួយបេក្ខជនបណ្ឌិត ដែលអាចមានឥទ្ធិពលដល់ការវាយតម្លៃ។ អ្នកពិនិត្យវាយតម្លៃ ត្រូវស្ថិតក្នុងស្ថានភាពមួយ ដែលអាចផ្តល់នូវការវាយតម្លៃដ៏សុក្រឹត លើគុណភាពនៃនិក្ខេបបទ។

១៤.៣- ដំណើរការការប្រឡងបញ្ចប់

- មុននឹងរៀបចំការការពារនិក្ខេបបទផ្ទាល់មាត់ គ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្ញើនិក្ខេបបទដែលសរសេរចប់សម្រាប់ឡើងការពារទៅអ្នកពិនិត្យវាយតម្លៃនិក្ខេបបទ
- ជាទូទៅ ក្រោយពីបានបំពេញគ្រប់លក្ខខណ្ឌសម្រាប់ការការពារ បេក្ខជនបណ្ឌិតត្រូវធ្វើការការពារនិក្ខេបបទផ្ទាល់មាត់ ដោយផ្ទាល់និងជាសាធារណៈ។

**មាត្រា ១៥.-**

ការពិនិត្យនិងវាយតម្លៃនិក្ខេបបទ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវផ្ញើទៅគ្រប់អ្នកពិនិត្យវាយតម្លៃ នូវនិក្ខេបបទមួយច្បាប់ និងព័ត៌មានទាក់ទងនឹងតម្រូវការនានាដែលអ្នកពិនិត្យវាយតម្លៃត្រូវធ្វើ
- ការពិភាក្សាជូនដំណឹងគ្នា រវាងអ្នកពិនិត្យវាយតម្លៃ និងសាស្ត្រាចារ្យណែនាំ និងបេក្ខជនបណ្ឌិត ត្រូវបានហាមឃាត់ជាដាច់ខាត មុនពេលរបាយការណ៍អំពីការវាយតម្លៃ មិនទាន់ដាក់ជូនផ្នែកទទួលបន្ទុកវគ្គបណ្ឌិត ឬគណៈកម្មការគ្រប់គ្រងវគ្គបណ្ឌិត
- ដំណើរការប្រឡងបញ្ចប់ ត្រូវចប់សព្វគ្រប់ នៅពេលបញ្ចប់ការការពារផ្ទាល់មាត់។ រាល់អនុសាសន៍ដែលបេក្ខជនបណ្ឌិតទទួលបានមុនពេលនោះ គឺជាអនុសាសន៍បណ្តោះអាសន្នប៉ុណ្ណោះ.
- បន្ទាប់ពីការពិនិត្យពិចារណាលើនិក្ខេបបទ អ្នកពិនិត្យ និងវាយតម្លៃ និក្ខេបបទ ត្រូវសរសេររបាយការណ៍ទៅគ្រឹះស្ថានឧត្តមសិក្សា។ របាយការណ៍របស់អ្នកពិនិត្យវាយតម្លៃនិក្ខេបបទ គឺជារបាយការណ៍ឯករាជ្យរៀងៗខ្លួន។

**មាត្រា ១៦.-**

ការរៀបចំទូទៅនៃការប្រឡងបញ្ចប់ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការពន្យល់ច្បាស់លាស់អំពីដំណើរការប្រឡងបញ្ចប់ ចាប់តាំងពីការចាប់ផ្តើមរបស់អ្នកពិនិត្យនិងវាយតម្លៃ រហូតដល់លទ្ធផលចុងក្រោយនៃការការពារផ្ទាល់មាត់។ ការពន្យល់នេះត្រូវចែកជូនដល់គ្រប់ភាគីពាក់ព័ន្ធ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានទម្រង់ជាលាយលក្ខណ៍អក្សរងាយយល់និងច្បាស់លាស់ សម្រាប់បំពេញដើម្បីជួយដំណើរការរដ្ឋបាល នៃកិច្ចការប្រឡងបញ្ចប់
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការទទួលខុសត្រូវ ក្នុងការរៀបចំការការពារផ្ទាល់មាត់ ដែលស្ថិតក្នុងពេលវេលាមួយត្រឹមត្រូវ និងច្បាស់លាស់
- ការការពារផ្ទាល់មាត់ ត្រូវស្ថិតនៅក្នុងបរិយាកាសសមស្រប ទីតាំងសក្តិសម មានសម្ភារៈគ្រប់គ្រាន់ និងស្វាគមន៍ការចូលរួមស្តាប់ជាសាធារណៈ។

**មាត្រា ១៧.-**

ការរៀបចំមុន សម្រាប់ការការពារផ្ទាល់មាត់ មានដូចខាងក្រោម៖

- ប្រធានផ្នែកបណ្ឌិត ឬក្រឹទ្យបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ ផ្ញើលទ្ធផលនៃការអាន និងវាយតម្លៃរបស់អ្នកពិនិត្យវាយតម្លៃ ទៅក្រុមសាស្ត្រាចារ្យណែនាំ គណៈមេប្រយោគ និងនិស្សិតយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនថ្ងៃឡើងការពារផ្ទាល់មាត់
- ការការពារផ្ទាល់មាត់ រៀបចំដោយប្រធានផ្នែកបណ្ឌិត ឬក្រឹទ្យបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ និងដែលជាប្រធានដឹកនាំការការពារផ្ទាល់មាត់។ ប្រធានផ្នែកបណ្ឌិត ឬក្រឹទ្យបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ អាចចាត់អ្នកតំណាងក្នុងករណីពុំអាចចូលរួមដឹកនាំបាន
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវព្យាយាមឲ្យមានការចូលរួម ពីសំណាក់អ្នកពិនិត្យវាយតម្លៃនិក្ខេបបទទាំងអស់ ក្នុងពេលការពារផ្ទាល់មាត់។ ករណីចាំបាច់ ត្រូវប្រើបច្ចេកវិទ្យាព័ត៌មានជាពិសេស សម្រាប់អ្នកពិនិត្យវាយតម្លៃមកពីបរទេស។ ក្នុងករណី អ្នកពិនិត្យវាយតម្លៃ មកពីបរទេសអវត្តមាន សំណួរទាំងអស់របស់គាត់ ត្រូវបានលើកយកមកចោទសួរ ក្នុងការការពារផ្ទាល់មាត់។ ក្រុមសាស្ត្រាចារ្យណែនាំត្រូវចូលរួមក្នុងការការពារផ្ទាល់មាត់ផងដែរ។ សាស្ត្រាចារ្យណែនាំគោល ដើរតួជាគណៈមេប្រយោគម្នាក់ដែរក្នុងការផ្តល់ពិន្ទុ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់នីតិវិធី សម្រាប់អនុវត្តនៅពេលដែលអ្នកពិនិត្យ និងវាយតម្លៃពុំឯកភាពគ្នា លើលទ្ធផលនៃការប្រឡងបញ្ចប់។

**មាត្រា ១៨.-**

ការរៀបចំសម្រាប់អំឡុងពេល ការពារផ្ទាល់មាត់ មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់របៀប នៃការការពារផ្ទាល់មាត់នូវនិក្ខេបបទថ្នាក់បណ្ឌិតផ្សេងៗគ្នា អាស្រ័យតាមជំនាញ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានរបាយការណ៍វាយតម្លៃដំបូង ជាលាយលក្ខណ៍អក្សរខ្លី រៀបចំឡើងដោយមានលក្ខណៈឯកភាពគ្នា ពីសំណាក់អ្នកពិនិត្យវាយតម្លៃនិក្ខេបបទ មុនពេលការពារផ្ទាល់មាត់ ដាក់ជូនគណៈមេប្រយោគទាំងអស់
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់ជាមុន នូវតារាងលទ្ធផលប្រឡង ដើម្បីឲ្យគណៈមេប្រយោគងាយស្រួលមានយោបល់ និងដាក់ពិន្ទុ និងដើម្បីរក្សាស្តង់ដាគុណភាពថ្នាក់បណ្ឌិត
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការកំណត់នីតិវិធីគ្រប់ដំណាក់កាល នៃដំណើរការប្រឡងដែលច្បាស់លាស់ និងងាយយល់។ ការកំណត់នេះ មានដូចជា៖

  ក- ការកំណត់និយាមនៃដំណើរការប្រឡង។

  ខ- ការកំណត់តួនាទី ភារកិច្ច និងការទទួលខុសត្រូវ របស់អ្នកពិនិត្យ និងវាយតម្លៃមកពីក្រៅ និងអ្នកពិនិត្យនិងវាយតម្លៃមកពីក្នុងគ្រឹះស្ថានឧត្តមសិក្សា សាស្ត្រាចារ្យណែនាំ និងគណៈមេប្រយោគ នៅពេលការពារផ្ទាល់មាត់។
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានគោលការណ៍ណែនាំ អំពីការការពារផ្ទាល់មាត់ ដែលផ្តោតទៅលើ៖

  ក- ទម្រង់និងកាលវិភាគនៃការការពារផ្ទាល់មាត់។

  ខ- រយៈពេលរួមនៃការការពារផ្ទាល់មាត់។

  គ- ការផ្តល់អនុសាសន៍ទៅបេក្ខជន នៅចុងបញ្ចប់នៃការការពារផ្ទាល់មាត់។

**មាត្រា ១៩..**

របាយការណ៍ក្រោយការការពារផ្ទាល់មាត់ មានដូចខាងក្រោម៖

- សេចក្ដីសម្រេចរបស់គណៈមេប្រយោគអាច មានមួយក្នុងចំណោមចំណុច ខាងក្រោម៖

  ក- និក្ខេបបទមានតម្លៃ ជានិក្ខេបបទកម្រិតបណ្ឌិត។

  ខ- និក្ខេបបទមានតម្លៃ ជានិក្ខេបបទកម្រិតបណ្ឌិត បន្ទាប់ពីមានការកែលម្អតិចតួច តាមការណែនាំរបស់មេប្រយោគ។ ក្នុងករណីនេះ និស្សិតនិងសាស្ត្រាចារ្យណែនាំធ្វើការកែលម្អ និងដាក់ជូនគ្រឹះស្ថានឧត្តមសិក្សាឡើងវិញ តាមការព្រមព្រៀងគ្នា។

  គ- និក្ខេបបទមានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត បន្ទាប់ពីមានការកែសម្រួលឡើងវិញ តាមការណែនាំរបស់មេប្រយោគ។ ក្នុងករណីនេះ និស្សិតនិងសាស្ត្រាចារ្យណែនាំ ត្រូវធ្វើការសេរសេរកែលម្អឡើងវិញ និងដាក់ជូនគ្រឹះស្ថានឧត្តមសិក្សា តាមការព្រមព្រៀងគ្នាជាមួយនឹងគណៈមេប្រយោគ។

  ឃ- និក្ខេបបទពុំទាន់មានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត ក៏ប៉ុន្តែបេក្ខជនអាចដាក់និក្ខេបបទ ដើម្បីពិនិត្យនិងវាយតម្លៃម្ដងទៀត ក្នុងរយៈពេលដែលកំណត់ ដោយគណៈមេប្រយោគ។ ក្នុងករណីនេះ មេប្រយោគត្រូវរៀបរាប់ពន្យល់លម្អិត អំពីមូលហេតុនិងអនុសាសន៍របស់ខ្លួន ឲ្យបានគ្បោះក្បាយ ដើម្បីជួយបេក្ខជន ក្នុងការទទួលបានជោគជ័យនាគ្រាក្រោយៗ និស្សិតនិងសាស្ត្រាចារ្យណែនាំត្រូវធ្វើការស្រាវជ្រាវ ឬសរសេរឡើងវិញតាមការផ្ដល់អនុសាសន៍ ដែលបានព្រមព្រៀងគ្នាជាមួយនឹងគណៈមេប្រយោគ មុនពេលកំណត់ថ្ងៃការពារផ្ទាល់មាត់ ឡើងវិញម្ដងទៀត។

  ង- សញ្ញាបត្របណ្ឌិត មិនត្រូវបានប្រគល់ជូន ហើយការចុះឈ្មោះជាបេក្ខជនបណ្ឌិត ត្រូវបានបញ្ចប់។

- នៅពេលដែលមេប្រយោគមានយោបល់ និងការវាយតម្លៃផ្សេងៗគ្នា លើលទ្ធផលនៃការប្រឡងបញ្ចប់ អ្នកវាយតម្លៃខាងក្នុង ត្រូវដើរតួជាអ្នកសម្របសម្រួល រវាងមេប្រយោគទាំងអស់ ដើម្បីដោះស្រាយបញ្ហា។ របាយការណ៍ចុងក្រោយរួមគ្នា និងឯកភាពគ្នាមួយ ត្រូវរៀបចំឡើងជូនប្រធានថ្នាក់បណ្ឌិត (ឬព្រឹទ្ធបុរស នៃថ្នាក់ក្រោយបរិញ្ញាបត្រ) ដោយអ្នកសម្របសម្រួល។ ក្នុងករណីពុំមានការឯកភាពគ្នាទេ ត្រូវយកមធ្យមភាគនៃពិន្ទុ ដែលផ្ដល់ឲ្យដោយគណៈមេប្រយោគទាំងអស់ជាលទ្ធផលក្នុងការចេញសញ្ញាបត្របណ្ឌិត

- មេប្រយោគទាំងអស់ ត្រូវមានការឯកភាពគ្នា និងចុះហត្ថលេខាលើរបាយការណ៍ នៃការការពារផ្ទាល់មាត់

- ប្រធានផ្នែកបណ្ឌិត ឬព្រឹទ្ធបុរសនៃថ្នាក់ក្រោយបរិញ្ញាបត្រ ដែលជាប្រធានគណៈកម្មការការពារបន្ទាប់ពីការការពារផ្ទាល់មាត់ ត្រូវផ្ញើរបាយការណ៍អំពីលទ្ធផល នៃការប្រឡងជារួមទៅគណៈកម្មការគ្រប់គ្រងថ្នាក់បណ្ឌិត

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានយន្តការប្ដឹងតវ៉ា ក្នុងករណីដែលនិស្សិត ឬសាស្ត្រាចារ្យណែនាំ ពុំយល់ព្រមលើលទ្ធផលនៃការប្រឡង។

# ជំពូកទី៤
# លក្ខខណ្ឌសម្រាប់ការផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស

**មាត្រា ២០.-**

គ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

- មានតែគ្រឹះស្ថានឧត្តមសិក្សា ដែលបានទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ឬគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដែលនិងធ្លាប់បានប្រគល់សញ្ញាបត្របណ្ឌិតប៉ុណ្ណោះ ទើបអាច ផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយសបាន
- គ្រឹះស្ថានឧត្តមសិក្សា អាចផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយសបាន តែនៅក្នុងជំនាញដែលមានការបណ្តុះបណ្តាល នៅក្នុងគ្រឹះស្ថានឧត្តមសិក្សានោះ តែប៉ុណ្ណោះ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវបង្កើតគណៈកម្មការ សម្រាប់បណ្ឌិតកិត្តិយស។ សមាសភាពនៃគណៈកម្មការនេះ ត្រូវចម្លងជូនជ្រាបទៅក្រសួងទទួលបន្ទុកវិស័យអប់រំ និងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ឬគណៈកម្មាធិការជាតិ បណ្តុះបណ្តាល
- ក្នុងមួយឆ្នាំសិក្សា គ្រឹះស្ថានឧត្តមសិក្សាមួយ អាចផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ជូនទៅត្រឹមតែបេក្ខជន២(ពីរ)រូប ប៉ុណ្ណោះ។

**មាត្រា ២១.-**

គោលការណ៍នៃការជ្រើសរើសបេក្ខជន ទទួលសញ្ញាបត្របណ្ឌិតកិត្តិយស មានដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ឲ្យបានច្បាស់លាស់ និងផ្សព្វផ្សាយជាសាធារណៈ នូវគោលការណ៍នៃការប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស
- បេក្ខជនទទួលសញ្ញាបត្របណ្ឌិតកិត្តិយស ពុំអាចជាអ្នករាជការសាធារណៈ ដែលកំពុងស្ថិតក្នុងតំណែងសំខាន់ មានឥទ្ធិពលដោយផ្ទាល់លើគ្រឹះស្ថានឧត្តមសិក្សា ដែលប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយសឡើយ
- បេក្ខជនទទួលសញ្ញាបត្របណ្ឌិតកិត្តិយស ពុំអាចជានិស្សិតដែលកំពុងសិក្សា ឬជាមន្ត្រីដែលកំពុងបម្រើការក្នុងគ្រឹះស្ថានឧត្តមសិក្សានោះបានឡើយ
- សញ្ញាបត្របណ្ឌិតកិត្តិយស ពុំត្រូវបានអនុញ្ញាតឲ្យប្រគល់ជូន ដើម្បីដោះដូរនឹងប្រាក់ លាភសក្ការៈ ឬសេវាកម្មណាមួយសម្រាប់គ្រឹះស្ថានឧត្តមសិក្សាឡើយ។ លើកលែងតែសកម្មភាពសប្បុរសធម៌ក្នុងអតីតកាល និងអនាគតក្នុងរយៈពេលវែងពុំមែនជាឧបសគ្គ ក្នុងការប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយសនេះទេ
- សញ្ញាបត្របណ្ឌិតកិត្តិយសគួរ ត្រូវប្រគល់ជូនបុគ្គលដែលបានរួមវិភាគទាន ក្នុងការកសាងព្រះរាជាណាចក្រកម្ពុជាជាចម្បង។

**មាត្រា ២២.**

ការជ្រើសរើសបេក្ខជន សម្រាប់ផ្តល់សញ្ញាបត្របណ្ឌិតកិត្តិយស ត្រូវអនុវត្តដូចខាងក្រោម៖

- គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ឲ្យបានច្បាស់លាស់ និងផ្សាយជាសាធារណៈពីកាលបរិច្ឆេទចុងក្រោយសម្រាប់៖
  - ក- ប្រធានផ្នែកក្រោយបរិញ្ញាបត្រ ឬផ្នែកបណ្ឌិតនៃគ្រឹះស្ថានឧត្តមសិក្សា ទទួលការស្នើតាំងបេក្ខជន ពីសាស្ត្រាចារ្យ។
  - ខ- បញ្ជីឈ្មោះនៃបេក្ខជន ដែលបានស្នើតាំងទាំងអស់ សម្រាប់ឆ្នាំសិក្សា ដើម្បីដាក់ជូននាយកគ្រឹះស្ថានឧត្តមសិក្សា និងជូនអង្គប្រជុំវាយតម្លៃសម្រេច។
  - គ- សំណុំឯកសារសម្រាប់បេក្ខជន ដែលបានស្នើតាំងផ្តាច់ព្រ័ត្រ សម្រាប់ការប្រជុំចុងក្រោយ។
  - ឃ- ការប្រជុំសម្រេចចុងក្រោយ។
- ការស្នើតាំងនីមួយៗ ត្រូវឆ្លងកាត់គណៈកម្មការជ្រើសរើស ដើម្បីធ្វើការវាយតម្លៃជម្រុះបេក្ខជនខ្លះ
- បេក្ខជន ដែលត្រូវបានជាប់ក្នុងបញ្ជីស្នើតាំងផ្តាច់ព្រ័ត្រ ត្រូវឆ្លងកាត់ការប្រជុំវាយតម្លៃចុងក្រោយ ការប្រជុំវាយតម្លៃនេះ ធ្វើការសម្រេចចិត្តឡើង ដោយផ្អែកលើលទ្ធផល នៃការពិនិត្យ និងវាយតម្លៃរបស់អនុគណៈកម្មការសម្រាប់បេក្ខជន ដែលបានស្នើតាំងនីមួយៗ
- អនុគណៈកម្មការពិនិត្យ និងវាយតម្លៃលើបេក្ខជន ដែលបានស្នើតាំងនីមួយៗ មានតួនាទីរៀបចំសំណុំឯកសារ សម្រាប់បេក្ខជនដែលបានស្នើតាំងម្នាក់។ សំណុំឯកសារនេះមានរៀបរាប់អំពីអាជីព និងស្នាដៃសំខាន់ៗរបស់បេក្ខជន ដែលបានស្នើតាំងផ្តាច់ព្រ័ត្រ និងជំនាញដែលត្រូវប្រគល់ជូន
- សេចក្តីសម្រេចចិត្តចុងក្រោយ ធ្វើឡើងតាមរយៈការបោះឆ្នោត របស់សមាជិកទាំងអស់ នៃគណៈ-កម្មការជ្រើសរើស។ សមាជិកដែលអវត្តមាន ត្រូវប្រគល់សិទ្ធិសម្រេចជូនប្រធានអង្គប្រជុំ ជាលាយលក្ខណ៍អក្សរ។ សញ្ញាបត្របណ្ឌិតកិត្តិយស អាចប្រគល់ជូនតែចំពោះបេក្ខជន ដែលទទួលបានសំឡេងគាំទ្រ ចាប់ពី២ភាគ៣ ឡើងទៅ
- ការប្រជុំសម្រេចចុងក្រោយ នៅកម្រិតគ្រឹះស្ថានឧត្តមសិក្សា មិនត្រូវធ្វើឡើងជាចំហ ឬជាសាធារណៈឡើយ
- គ្រឹះស្ថានឧត្តមសិក្សា ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យអប់រំ ដើម្បីចេញសញ្ញា-បត្របណ្ឌិតកិត្តិយស ជូនបេក្ខជន ក្រោយពីពេលការសម្រេចជាចុងក្រោយរួចរាល់។

**មាត្រា ២៣.**

គោលការណ៍នៃការរៀបចំឯកសារពាក់ព័ន្ធ និងការប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស អាចមានភាពប្រែប្រួលពីបេក្ខជន ដែលបានស្នើតាំងចុងក្រោយម្នាក់ ទៅបេក្ខជនដែលបានស្នើតាំងចុងក្រោយម្នាក់ទៀត អាស្រ័យដោយព័ត៌មានដែលបានទទួល។ ទោះជាយ៉ាងណាក្តី សំណុំឯកសារសម្រាប់បេក្ខជន ដែលបានស្នើតាំងចុងក្រោយម្នាក់ៗដែលមិនអាចខ្វះបាន មានដូចខាងក្រោម៖

១- ប្រវត្តិរូបរបស់បេក្ខជន ដែលបានស្នើតាំងចុងក្រោយ ដែលបរិយាយអំពីការអប់រំ ការងារ ងារ និងការលើកទឹកចិត្តនានា។

២- ការវិភាគនិងវាយតម្លៃលើជោគជ័យ ឬស្នាដៃរបស់របស់បេក្ខជន ដែលបានស្នើតាំងចុងក្រោយ ដោយមានការបញ្ជាក់ថា តើជោគជ័យឬស្នាដៃនោះមានទំនាក់ទំនងយ៉ាងណា ជាមួយ គ្រឹះស្ថានឧត្តមសិក្សា ជាមួយកម្ពុជា ឬជាមួយមនុស្សជាតិទាំងមូល។

## ជំពូកទី៥

## យន្តការត្រួតពិនិត្យដើម្បីធានាគុណភាពលើការបណ្តុះបណ្តាលថ្នាក់បណ្ឌិត

**មាត្រា ២៤.-**

គ្រប់ទម្រង់នៃការត្រួតពិនិត្យទូទៅ នៃវគ្គបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវធ្វើឡើងដោយផ្អែកលើបីចំណុចសំខាន់ៗ ដូចខាងក្រោម៖

១- រដ្ឋបាលនិងការគ្រប់គ្រងរបស់គ្រឹះស្ថានឧត្តមសិក្សា។

២- ការស្រាវជ្រាវនិងការផ្សព្វផ្សាយរបស់គ្រឹះស្ថានឧត្តមសិក្សា។

៣- ការបណ្តុះបណ្តាលរបស់គ្រឹះស្ថានឧត្តមសិក្សា។

**មាត្រា ២៥.-**

កម្មវត្ថុនៃការត្រួតពិនិត្យមាន ដូចខាងក្រោម៖

- ការត្រួតពិនិត្យលើរដ្ឋបាលនិងការគ្រប់គ្រង ធ្វើការវាយតម្លៃលើភាពសមស្របនៃ ទីតាំងសិក្សាសមាស-ភាពសាស្ត្រាចារ្យ និងធនធានហិរញ្ញវត្ថុ ដែលអាចធានាឲ្យមានដំណើរការ នៃវគ្គបណ្តុះបណ្តាលមួយប្រកបដោយគុណភាព
- ការត្រួតពិនិត្យលើការស្រាវជ្រាវ និងផ្សព្វផ្សាយរបស់គ្រឹះស្ថានឧត្តមសិក្សា ធ្វើការវាយតម្លៃលើការបង្កើតអង្គភាពស្រាវជ្រាវ ដំណើរការស្រាវជ្រាវ និងការផ្សព្វផ្សាយរបស់គ្រឹះស្ថានឧត្តមសិក្សា។ គ្រឹះស្ថានឧត្តមសិក្សា ដែលដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវមានអង្គភាពស្រាវជ្រាវដែលផ្សារភ្ជាប់ការងាររបស់ខ្លួនយ៉ាងសកម្ម ជាមួយផ្នែកបណ្តុះបណ្តាល។ រៀងរាល់លទ្ធផលនៃកិច្ចការស្រាវជ្រាវ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវដទៃទៀត។ ការផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវ របស់គ្រឹះស្ថានឧត្តមសិក្សា ដែលដំណើរការថ្នាក់បណ្ឌិត អាចធ្វើតាមរយៈរូបភាពផ្សេងៗ ជាអាទិ៍ ទស្សនាវដ្តីប្រចាំឆ្នាំ (ឬឆមាស ឬត្រីមាស) ឯកសារពិភាក្សាសិក្ខាសាលាជំនាញ ឬតាមរូបភាពផ្សេងៗទៀត
- ការត្រួតពិនិត្យលើការបណ្តុះបណ្តាល ធ្វើការវាយតម្លៃលើគ្រប់ដំណាក់កាល នៃការបណ្តុះបណ្តាលគិតចាប់ពីការប្រឡងជ្រើសរើសនិស្សិត ការសិក្សាជាមួយនឹងសាស្ត្រាចារ្យ ការស្រាវជ្រាវ ការសរសេរនិក្ខេបបទ និងការប្រឡងបញ្ចប់វគ្គសិក្សា។ ការត្រួតពិនិត្យការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវធ្វើឡើងដោយឈរលើគោលការណ៍ធានាគុណភាពកម្រិតបណ្ឌិត នៅព្រះរាជាណាចក្រកម្ពុជា ភាពឯករាជ្យផ្នែកវិជ្ជាជីវៈនៃគ្រឹះស្ថានឧត្តមសិក្សា និងការកាត់បន្ថយឲ្យបានជាអតិបរមា នូវកម្រិតការិយាធិបតេយ្យសំដៅធានាឲ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការគ្រប់គ្រងពេលវេលា និងធនធាននៃការបណ្តុះបណ្តាល។

**មាត្រា ២៦.-**

យន្តការត្រួតពិនិត្យនិងវាយតម្លៃគុណភាព មានដូចខាងក្រោម៖

- យន្តការត្រួតពិនិត្យដើម្បីធានាគុណភាព លើការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ជាកិច្ចសហការរវាងក្រសួងទទួលបន្ទុកវិស័យអប់រំ ជាមួយក្រសួង ស្ថាប័នដែលមានគ្រឹះស្ថានឧត្តមសិក្សាបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ត្រូវមាននាយកដ្ឋានទទួលស្គាល់គុណភាពអប់រំថ្នាក់ក្រោយបរិញ្ញាបត្រ ដើម្បីវាយតម្លៃទទួលស្គាល់គុណភាពថ្នាក់បណ្ឌិត និងសហការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការកំណត់ស្តង់ដាគុណភាពអប់រំអប្បបរមា សម្រាប់ការវាយតម្លៃទទួលស្គាល់គុណភាពថ្នាក់បណ្ឌិត។

**មាត្រា ២៧.-**

ការលើកកម្ពស់កិច្ចការស្រាវជ្រាវ មានដូចខាងក្រោម៖

- កិច្ចការស្រាវជ្រាវ គឺជាលក្ខខណ្ឌចាំបាច់មួយ ដែលមិនអាចខ្វះបាន ក្នុងគ្រឹះស្ថានឧត្តមសិក្សាជាពិសេសគ្រឹះស្ថានឧត្តមសិក្សាដែលមានបណ្តុះបណ្តាលថ្នាក់បណ្ឌិត។ គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតបរិយាកាសឲ្យគ្រឹះស្ថានឧត្តមសិក្សា ជំរុញសកម្មភាពស្រាវជ្រាវរបស់ខ្លួន តាមរយៈគ្រប់រូបភាព
- ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវដើរតួជាអ្នកសម្របសម្រួលថ្នាក់ជាតិ សម្រាប់ការស្រាវជ្រាវ និងសកម្មភាពស្រាវជ្រាវកម្រិតជាតិ ដែលមានលក្ខណៈលំបាកស្មុគស្មាញ។

**មាត្រា ២៨.-**

- សេចក្តីណែនាំលម្អិតពាក់ព័ន្ធនឹងដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងយន្តការត្រួតពិនិត្យគុណភាពបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យអប់រំ
- ស្តង់ដាគុណភាពអប្បបរមានិងយន្តការវាយតម្លៃ ដើម្បីទទួលស្គាល់គុណភាពថ្នាក់បណ្ឌិត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- ស្តង់ដាជាតិសមត្ថភាពបណ្តុះបណ្តាលត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ២៩.-**

គ្រឹះស្ថានឧត្តមសិក្សា ដែលកំពុងដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនាពេលបច្ចុប្បន្ន មានរយៈពេល ១ (មួយ)ឆ្នាំ ដើម្បីកែលម្អឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

គ្រឹះស្ថានឧត្តមសិក្សា ដែលទើបចាប់ផ្តើមបើកដំណើរការបណ្តុះបណ្តាលថ្នាក់បណ្ឌិត ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះ មុននឹងដំណើរការបណ្តុះបណ្តាល។

ប្រធានបទស្រាវជ្រាវរបស់និស្សិតថ្នាក់បណ្ឌិត ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ របស់គណៈកម្មាធិការជាតិ រៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំការការពារសារណា និងនិក្ខេបបទ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា ៣០.**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣១.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ